# តំណក់ទឹកស្អាត!



ឱ! ខ្មែរអើយខ្មែរ! ពេលឮពួកយើងនិយាយថា ពួកយើង ស្រលាញ់អំពើល្អ ការពារអំពើល្អ និងដាំពង្រីកអំពើល្អ ពួក អ្នកបែរជានិយាយថា ពួកយើងមិនចេះរបៀបរស់នៅ! មិនចេះប្រើជីវិតអោយសប្បាយៗ! រស់មិនចុះចំណោមគេ! មិនចូលស្ទឹងតាមបទជាដើម។ ពេលឮពួកយើងនិយាយថា ពួកយើងស្អប់អំពើអាក្រក់ ហើយកំពុងរួមគ្នាកម្ទេចអំពើ អាក្រក់ ពួកអ្នកចោលភ្នែកមើលមកយើង ប្រៀបដូចជា យើងនេះជាសត្វចម្លែកដែលមានក្បាលពីរ ជើងបីអញ្ចឹង។ ប្រជាពលរដ្ឋខ្មែរបច្ចុប្បន្នធ្វើអាក្រក់លែងខ្មាស់ លែងស្គាល់ ពាក្យថា ខ្លើមបាប តែវាទៅជាខុសគេ មិនច្រលំគេ នៅពេល ដែលយើងហៅគេឲ្យនាំគ្នាបែរមកធ្វើអំពើល្អ។

ពេលយើងថា អ្វីៗត្រូវផ្តើមចេញពីការមានសម្មាទិដ្ឋិ គួរនាំ គ្នារៀន នាំគ្នាធ្វើបុណ្យទីភ្លី នោះគឺការធ្វើបុណ្យជួយជាតិ ដោយគ្មានរំពឹងផលតបស្នងមកខ្លួនវិញ។ គេថាស្អីគេ! វា មិនដែល! វាមិនដែលមានមនុស្សជួយគេដោយមិនគិតរក ផលប្រយោជន៍មកខ្លួនវិញ!!! វាមិនដែលមាននរណាធ្វើ នយោបាយមិនចង់បានអី! គតិមួយបានលើកឡើងថា ការជួយអ្នកដទៃគឺជាការចុះទុនរយៈពេលវែង ដែលនឹង ទទួលបានកម្រៃច្រើនពេលក្រោយ។ ការគិតបែបនេះក៏ នៅតែស្ថិតក្នុងព្រំដែននៃភាពអាត្មានិយមដដែល បែបនេះ ក៏មិនមែនជាការជួយសង្គ្រោះដែរ តែជាការដាក់នុយស្ទូច យកប្រយោជន៍ទៅវិញទេ។ ការជួយពិតប្រាកដប្រៀបដូច ជាទឹកហូរដែលហូរទៅមិនត្រលប់។ តែគេនៅតែប្រើគតិ ចាស់ថា "ទាល់តែវាមានទៅ បានវាមានមក"។ ពិតណាស់ បើនិយាយពីការជួយគ្នា តែងតែមានទៅមានមកពឹងពាក់ អាស្រ័យគ្នាមែន។ ប៉ុន្តែត្រង់ចំណុចនេះ យើងចង់និយាយ ពីគំនួចចិត្តដំបូងដែលគិតចង់ជួយនោះ គឺត្រឹមតែជួយ ជួយឲ្យអ្នកដែលយើងយល់ថាត្រូវការជំនួយ ត្រូវបានជួយ តែប៉ុណ្ណោះ មិនមែនគំនួចចិត្តថា ជួយគេថ្ងៃនេះស្អែកចាំ គេជួយវិញនោះទេ។ ផ្នែកមួយនៃការជួយ គឺប្រៀបដូច ជាការបម្រើដែលមិនគិតកម្រៃតបស្នង តែគឺជាទឹកចិត្ត ដែលគិតត្រឹមតែឲ្យ គឺឲ្យដោយគ្មានបង្កនូវស្លាកស្នាម អកុសលណាមួយត្រលប់មកខ្លួនវិញសោះឡើយ។ តើអ្នក ធ្លាប់ស្រោចទឹករុក្ខជាតិណាមួយ ដោយក្នុងចិត្តគ្រាន់តែ ញញឹមថាទឹកមួយផ្តិលនេះ សូមអោយឯងបានធំធាត់ដុះ លូតលាស់ដែរទេ? វាជាអារម្មណ៍អាណិតអាសូរដែល ឃើញរុក្ខជាតិនោះស្លោកស្រពោនរៀបងាប់ ហើយក៏ដួស ទឹកមួយផ្តិលទៅស្រោចលើវា ដែលទង្វើនេះមានត្រឹមតែ មេត្តាករុណាតែប៉ុណ្ណោះ។

មួយជីវិតមានត្រឹមរំញ័រៗនៃចិត្ត ដែលគិតចង់ទៅសង្គ្រោះ ចង់ទៅចែករំលែក ចង់ទៅជួយមនុស្សជុំវិញ ក្នុងខណៈ ដែលខ្លួនមានលទ្ធភាពជាង គឺចិត្តចង់អោយគេអាចរស់ នៅដោយសន្តិភាព ប្រកបដោយការរីកចម្រើន ដែលទឹក ចិត្តបែបនេះបន្តិចម្តងៗ បានប្រែក្លាយជាការងារប្រចាំ ជីវិតរបស់យើង។ យើងពេញចិត្តរស់ដើម្បីបានធ្វើការបែប នេះ គឺរស់ដើម្បីបានជាប្រយោជន៍ដល់មនុស្សជុំវិញ មិន មែនថាពិភពលោកនេះ មាន ឬគ្មានយើងគឺដូចតែគ្នានោះ ទេ ហើយយើងក៏ពេញចិត្តនឹងធ្វើការងារនេះ។ យើងមាន

ក្ដីសុខបន្ថែមរឿយៗនឹងធ្វើការងាររបស់យើង។ ការណ៍នេះវាបានមកបំពេញបន្ថែមភាពជាមនុស្សរបស់យើង។

"Sunflower" បកប្រែជាខ្មែរ មានន័យត្រង់ថា "ផ្កាព្រះអាទិត្យ" ដែលខ្មែរយើងហៅថា "ផ្កាឈូករ័ត្ន"។ ផ្កានេះមិនត្រឹមតែមានឈ្មោះជា "ផ្កាព្រះអាទិត្យ" និងមានរូបរាងដូចព្រះអាទិត្យកំពុងពេញពន្លឺប៉ុណ្ណោះទេ តែអ្វីដែលគួរឲ្យកោតសរសើរនោះ គឺផ្កាឈូករ័ត្នតែងតែរីកបែរទៅរកទិសថ្ងៃរះជាដរាប។ មិនថាយើងដាក់វាដាំនៅឯណា ដាំចំនួនប៉ុន្មានដើមមុខផ្ទះ ឬដាំរាប់ហិចតាដើម្បីយកគ្រាប់ នៅតាមតំបន់ណាលើពិភពលោកនេះ ក៏ផ្កាប្រភេទនេះតែងតែនាំគ្នាបែរទៅរកទិសថ្ងៃរះជានិច្ច។ នេះហើយជាលក្ខណៈពិសេសរបស់ផ្កាឈូករ័ត្ន នេះហើយជាចំណុចដែលមនុស្សគួរយកមកគិត។

ហេតុអ្វីទើបផ្កាឈូករ័ត្ន អាចបែរទៅរកទិសថ្ងៃរះបានដូចៗគ្នាម្ល៉េះ? វាជាធម្មជាតិរបស់ផ្កាប្រភេទនេះ ដែលមានគោលរួមសកលមួយរបស់វាសម្រាប់ផ្ទៀង នោះគឺទិសថ្ងៃរះ។ ពិតជាគួរឲ្យស្ងើចសរសើរសំណាងផ្កាប្រភេទនេះខ្លាំងណាស់ ដែលវាមានគោលសកលមួយដើម្បីតម្រង់ទិស។ មិនថាដុះតែឯងមួយដើម ឬមួយចំការឡើយ ផ្កាដែលដុះមួយដើមតែឯង មិនដែលយំឈឺចិត្ត ខ្លាចផ្កាប្រភេទដទៃសើចចំអក ដែលវាខំងាកបែរផ្ការបស់ខ្លួន ឲ្យរីកបែរទៅរកថ្ងៃរះសោះឡើយ។ វាពិតជាអស្ចារ្យខ្លាំងណាស់! នេះហើយជាឥស្សរៈ ជាសេរីភាពរួចផុតពីការគាបសង្កត់ ដែលវាផ្ទុយស្រលះពីផ្កាជ័រ ដែលមិនអាចងាកក្បាលទៅរកទិសថ្ងៃរះបាន ផ្ទុយទៅវិញវាតែងត្រូវបានមនុស្សកាច់កវាបង្ខិលទៅរកទិសណាដែលគេចង់ឲ្យវាបែរទៅ។ គ្មានឥស្សរៈទេ គ្មានតម្លៃក្នុងការរស់ទេ។

ត្រលប់ទៅពាក្យឧទានពីខាងដើមដែលគេថា "អីគេវាមិនដែលមានមនុស្សជួយគេដោយមិនចង់បានប្រយោជន៍មកខ្លួនវិញ!" មនុស្សអាត្មានិយមទាំងឡាយដែលមានចិត្តគគ្រិច តែងតែយកចិត្តដ៏កខ្វក់របស់ខ្លួនទៅគិតជំនួសអ្នកដទៃ ថាអ្នកដទៃក៏ថោកទាបដូចខ្លួនដែរ។ គេថាវាមិនដែលមាននោះ គឺមានន័យថា បើជាគេវិញ គេមិនទៅឆ្កួតធ្វើអ្វីដែលជាប្រយោជន៍អ្នកដទៃ ដោយមិនបានមកខ្លួនអញ្ចឹងទេ។ ពួកគេគិតថា នរណាក៏ធ្វើនយោបាយ ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ដូចជាបុណ្យសក្តិ លាភសក្ការៈអ្វីមួយដែរ ព្រោះថា មនុស្សអាក្រក់ខ្លះ អាក្រក់ក្រៃណាអាក្រក់ អាក្រក់រហូតដល់ពាល់មិនត្រូវថាដូចម្តេចទៅជាសេចក្តីល្អ ដែលជាការជួយសង្គ្រោះអ្នកដទៃដោយចិត្តសង្គ្រោះដ៏បរិសុទ្ធ ប្រាសចាកផលប្រយោជន៍ផ្ទាល់ខ្លួន។

មនុស្សដែលជួយគេពិតប្រាកដ មានគោលសកលមួយសម្រាប់ផ្ទៀង ដូចផ្កាឈូករ័ត្ន ដែលមានព្រះអាទិត្យជាគោលដូច្នេះដែរ ពោលគឺឈរតែលើភាពត្រឹមត្រូវ ប្រកបដោយដួងចិត្តសប្បុរស និងមានក្បាលនៅលើ ក នោះគេអាចរកការងារសម្រាប់ជីវិតគេបានហើយ។ ការសើចយំរបស់មនុស្សជុំវិញ លែងមានឥទ្ធិពលលើទង្វើរបស់គេហើយ។ ជីវិតនេះមិនមែនរស់ព្រោះតែមិនទាន់ស្លាប់ មិនមែនរស់ព្រោះតែមិនទាន់ដាច់ដង្ហើមទេ តែគឺជីវិតដែលរស់ដើម្បីធ្វើប្រយោជន៍។

ឈរលើគោលការណ៍នេះហើយ ធ្វើឲ្យយើងអាចមើលឃើញយ៉ាងច្បាស់ នូវភាពខុសស្រលះពីគ្នារវាងអ្នកដឹកនាំប្រទេសជាតិ ដែលមួយជាប្រភេទមនុស្សអាត្មានិយមត្រឹមធ្វើម៉េចឲ្យតែរក្សាអំណាចអញឲ្យបាន។ ឯអ្នកដឹកនាំមួយប្រភេទទៀត ដែលមានលក្ខណៈជាផ្កាឈូករ័ត្ន គឺគិតតែរំពៃធ្វើដូចម្តេចដើម្បីស្រោចស្រង់ជាតិឲ្យបាន។ គោលផ្ទៀងរបស់គេគឺជួយៗ ជួយដោយបេះដូងសង្គ្រោះ។ សូមក្រលេកមើលចុះ ថាមនុស្សប្រភេទទីមួយមានច្រើនលើសលប់ប៉ុណ្ណានៅស្រុកខ្មែរយើង? ទាំងអ្នកដឹកនាំបក្សកាន់អំណាច ទាំងអ្នកដឹកនាំបក្សប្រឆាំង ក្នុងបេះដូងរបស់គេសរសេរមិនចេញអក្សរ "ជួយជាតិ អាណិតប្រជាពលរដ្ឋ" សោះឡើយ គេរិះរកតែវិធីណាដែលអាចឲ្យខ្លួនគេ ឈរជើងជាប់លើទីលាននយោបាយ ដោយមិនខ្វល់ពីទុក្ខវេទនារបស់ប្រជាពលរដ្ឋ។ ឯអ្នកវិភាគនយោបាយទាំង

ឡាយ ទាំងអ្នកហៅខ្លួនថាជាអ្នកវិភាគឯករាជ្យ ទាំងមិនឯករាជ្យ ក៏ទៅណាមិនឆ្ងាយពីយុទ្ធសាស្ត្ររបស់អ្នកនយោបាយទុច្ចរិតទាំងនោះដែរ។ គេវិភាគលិច បូកកើត ទាញហេតុពីជើង បង្គ្រប់ពីត្បូងតាមក្រោយកន្ទុយរបស់អ្នកនយោបាយទុច្ចរិត ដោយសរុបមកនៅត្រឹមថា លោកនេះ ឬលោកនោះ បក្សនេះ ឬបក្សនោះ នឹងទ័លច្រកគ្មានផ្លូវដើរនឹងបញ្ចប់ជីវិតនយោបាយបែបនេះ ឬបែបនោះ។ មិនឮសោះឡើយការវិភាគដែលភ្ជាប់ថា បើដើរបែបនេះទៅបក្សនោះអាចដល់ផ្លូវទ័ល តែការធ្វើបែបនោះជាតិនឹងរស់។ អ្នកចេះដឹងខ្លះពេលវិភាគ គឺតែងបោះសកម្មភាពធ្វើឲ្យមកគេ តែបែរមើលទៅអ្នកវិភាគ ជើងមិនជាប់ដីសោះ គឺគេមិនឈរលើស្ថានភាពជាក់ស្តែងរបស់ខ្មែរឡើយ។ ពេលវិភាគរួចគេបោះឲ្យអ្នកនយោបាយ ដោយគេយល់ថា គេមិនមែនជាអ្នកនយោបាយ ហើយគេប្រាប់ប្រជាពលរដ្ឋបែបនេះ ឬបែបនោះ ក្នុងន័យថាគេមិនមែនជាប្រជាពលរដ្ឋឡើយ។ នាទីគេកើតមកដើម្បីត្រឹមតែវិភាគ រួចបោះឲ្យអ្នកដទៃយកទៅធ្វើតែប៉ុណ្ណោះ។

ឱ! ប្រជាពលរដ្ឋខ្មែរដែលជាអ្នកនិយមធ្វើបុណ្យដាក់ទានទាំងឡាយអើយ! ការធ្វើបុណ្យពិតប្រាកដ ក្នុងខណៈដែលប្រទេសកំពុងតែមានបញ្ហាបែបនេះ នោះគឺការធ្វើបុណ្យជួយជាតិ! ធ្វើបុណ្យទីភ្លឺដែលអាចយល់បាន នោះទើបជាការជួយខ្មែរពិតប្រាកដ។ ប្រជាពលរដ្ឋដែលមានឈ្មោះជាជនក្រីក្រ រួមទាំងជនដែលងាយក្រីក្រ មានចំនួនជាង ៨៥ ភាគរយនៃប្រជាពលរដ្ឋសរុប កំពុងតែស្រេកឃ្លាន កំពុងតែត្រូវការជំនួយ កោតតែចិត្តបងប្អូនអាចយកបាយបិណ្ឌទៅគ្រវាត់ចោលក្នុងវត្ត ដែលវត្តមានដល់ទៅជាង ៤ ពាន់វត្តទូទាំងប្រទេសកើត? មើលទៅក្លោងទ្វារវត្ត មើលទៅខឿនព្រះវិហារ ភ្លឺចែងចាំង តែកុំមើលផ្ទះស្លឹករខេករខាកជុំវិញរបងវត្ត។ មិនដឹងថាធ្វើដើម្បីអីហ្នរូបចម្លាក់ក្បាច់ក្បូរ ដែលគេដាក់តាំងស្ទៃតាមរបងវត្ត? បើចង់និយាយថាធ្វើដើម្បីរក្សាវប្បធម៌ស្នាដៃស្ថាបត្យកម្មក៏ថាចេះតែបាន តែតើស្នាដៃនោះវាអស្ចារ្យ វាមានតម្លៃជាងប្រជាពលរដ្ឋដែលរស់នៅក្បែររបងវត្ត ដាច់ពោះនឹងអត់បាយប៉ុណ្ណាទៅ?

ខ្លះជិះយន្តហោះយកមាសទៅបូជាធ្មេញព្រះសម្មាសម្ពុទ្ធនៅប្រទេសឥណ្ឌា។ ពួកអ្នកសាសនាទាំងនោះ នាំគ្នាធ្វើតែបុណ្យប្រាថ្នាតែឋានសួគ៌ ដើម្បីតែអញៗៗទៅវិញ។ តើវារីកចម្រើនលឿនប៉ុណ្ណាទៅ បើប្រជាពលរដ្ឋខ្មែរចេះធ្វើបុណ្យទីភ្លឺជួយសង្គ្រោះប្រទេសជាតិ? ចេះធ្វើបុណ្យអភិវឌ្ឍជាតិ? ពេលនោះទើបជីវិតរស់នៅរបស់មនុស្សម្នាក់ៗពោរពេញទៅដោយសារៈ។ ការងារបែបនេះ បើនិយាយចំពោះមនុស្សអាត្មានិយម គេប្រាកដជាមិនយល់ឡើយ គេរកមិនឃើញថ្ងៃពាល់ត្រូវក្តីសោមនស្សរីករាយដែលពួកយើងបានទទួលពីសកម្មភាពជួយចូលរួមពង្រីកអំពើល្អប្រចាំថ្ងៃរបស់យើងឡើយ។ វាជាប្រភេទភាពរីករាយ ភាពពេញចិត្ត ភាពមិនជំពាក់ចិត្ត ដែលមនុស្សអាត្មានិយមយល់មិនបាន។

ជាធម្មតាក្នុងប្រទេសមួយ គឺមានទាំងមនុស្សអាត្មានិយម (មនុស្សអាក្រក់) និងមនុស្សដែលមានបេះដូងសប្បុរស (មនុស្សល្អ) រស់នៅលាយឡំគ្នា។ គ្មាននរណាម្នាក់អាចធ្វើឲ្យមនុស្សទាំងអស់ប្រែទៅជាល្អទាំងអស់មួយប្រទេសបានឡើយ។ យើងចង់សំដៅដល់ ការចូលរួមគ្នាលើកស្ទួយមនុស្សល្អប្រកបដោយធម៌ឲ្យមកកាន់ការងារប្រទេសជាតិ។ កិច្ចការនេះអាចសម្រេចទៅបាន គឺត្រូវអាស្រ័យលើប្រជាពលរដ្ឋ។ គេច្រើនតែយល់ថា អ្នកដឹកនាំល្អនាំឲ្យប្រជាពលរដ្ឋមានគុណភាព។ ពិតជាបែបនេះមែន! តែសូមក្រលេកមកមើលសកម្មភាពជាក់ស្តែងរបស់ខ្មែរយើងវិញ។ តើយើងត្រូវនៅដេករង់ចាំព្រះបាទធម្មិក ជិះសេះសកាន់លំពែងជ័យ មកជួយជប់អោយប្រជាពលរដ្ឋខ្មែរមានគុណភាពទៅឬ? យើងច្បាស់ណាស់ថា បើដេកចាំឲ្យអ្នកដឹកនាំល្អណានោះផុសមកជួយខ្មែរ ក្រែងតែដល់ពេលនោះប្រជាពលរដ្ឋខ្មែរដាច់ពូជអស់ ឬក៏ក្លាយទៅជាជនជាតិភាគតិចលើដីកំណើតរបស់ខ្លួនមុនបាត់ទៅហើយ ទម្រាំនឹងមាន "គេមកធ្វើឲ្យល្អឲ្យ" នោះ។ យើងសំឡឹងមើលទៅឃើញមានច្រកចេញតែមួយគត់ គឺយើងជាប្រជាពលរដ្ឋនេះ ត្រូវតែក្រោកឡើងមកចូលរួមជួយរុញច្រាន បង្កើតឲ្យបានអ្នកដឹកនាំល្អ ដែលត្រូវរើសចេញពីចំណោមពួក

យើងទាំងអស់គ្នាដែលជាជនរងគ្រោះនេះ។ បែបនេះទើបអ្នកដឹកនាំម្នាក់នោះ ជាតំណាងពិតប្រាកដរបស់ពួកយើង។ មានតែវិធីនេះមួយគត់ ទើបឆ្លើយតបទៅនឹងនិយមន័យដើមរបស់រដ្ឋាភិបាលប្រជាធិបតេយ្យ "**កើតពីប្រជាពលរដ្ឋ របស់ប្រជាពលរដ្ឋ និងដើម្បីប្រជាពលរដ្ឋ**"។ ក្នុងន័យថា គុណភាពរបស់បុគ្គលដែលយើងរើសបាន ត្រូវអាស្រ័យលើគុណភាពរបស់ពួកយើងដែលជាអ្នករើស។ ក្រោយពេលរើសបានអ្នកដឹកនាំដែលមានគុណភាពបែបនោះរួចហើយ អ្នកដឹកនាំនោះនឹងជំរុញឲ្យប្រជាពលរដ្ឋដែលមានគុណភាពខ្លះស្រាប់ហើយនោះ កាន់តែមានគុណភាពល្អថែមទៀត។ ដល់ពេលនោះ ពួកយើងនឹងឈានហួសពីជំលោះថាតើប្រជាពលរដ្ឋល្អបង្កើតអ្នកដឹកនាំល្អ? ឬអ្នកដឹកនាំល្អបង្កើតប្រជាពលរដ្ឋល្អ? ខណៈនោះ ទាំងប្រជាពលរដ្ឋ ទាំងអ្នកដឹកនាំសុទ្ធតែដឹង និងបំពេញកាតព្វកិច្ចរបស់ខ្លួនរៀងៗខ្លួនប្រកបដោយទំនួលខុសត្រូវ។

នៅពេលមានមនុស្សគិតថា អាល់បឺត អាញស្តាញឆ្កួត គាត់បាននិយាយថា មនុស្សដែលឆ្កួតបំផុត គឺប្រភេទមនុស្សដែលធ្វើតែរឿងដដែលៗដូចមុន តែបែរជាដេករំពឹងចាំទទួលលទ្ធផលផ្សេងដែលប្រសើរជាងមុន! តើគតិនេះឆ្លុះបញ្ចាំងបែបណា មកលើសកម្មភាពរបស់ប្រជាពលរដ្ឋខ្មែរយើងពេលនេះ? បងប្អូនប្រជាពលរដ្ឋទាំងឡាយគប្បីយល់ថា ដើម្បីបានផ្លែផ្កា លុះត្រាតែយើងធ្វើការដាំដុះជាមុនសិន។ បើយើងមិនព្រមដាំទេ ហើយដេកចាំទទួលផល លុះត្រាតែយើងទៅសុំគេ ទៅលួចគេ ឬទៅរើសសំណល់ពីគេ។ ខ្មែរប្រាថ្នាចង់បានណាស់ផលពីប្រជាធិបតេយ្យ តែខ្មែរមិនបានធ្វើឲ្យគ្រប់ហេតុ ដើម្បីទទួលបានផលប្រជាធិ-បតេយ្យដែលខ្លួនចង់បាន ក្រៅពីការដេកយំ ដេរគេ បន់ស្រន់បួងសួង ដាក់បណ្តាសារ និងសុំប្រជាធិបតេយ្យពីគេមិនឈប់ទៅវិញ។ ប្រជាពលរដ្ឋនៅក្នុងប្រទេសរីកចម្រើនមិនមែននៅស្ងៀមៗ ទទួលបានផលទេ តែគឺដូនតាគេរួមទាំងរូបគេគ្រប់ៗគ្នាផង បានបំពេញកាតព្វកិច្ចក្នុងនាមជាម្ចាស់ប្រទេស ដើម្បីទទួលបានមកវិញនូវសិទ្ធិជាម្ចាស់ប្រទេសនោះ។

ដូចដែលបានជម្រាបជូនខាងលើរួចហើយថា លុះត្រាតែយើងជាប្រភេទពលដែលមានគុណភាពដែរ ទើបយើងអាចទៅចូលរួមគ្នា ជ្រើសបានប្រមុខដែលមានគុណភាព។ មើលចុះប្រជាពលរដ្ឋខ្មែរមិនជាខ្វះទេ ទឹកចិត្តស្នេហាជាតិម្នាក់ៗចង់ឲ្យប្រទេសរួចផុតពីរបបផ្តាច់ការជិះជាន់ តែសួរថាឯណាទៅក្បាល? ក្បាលនៅឯណា? ថាប្រជាពលរដ្ឋទៅមិនដឹងថាក្បាលពិតប្រាកដរបស់ខ្លួននៅឯណា ចុះអ្នកដែលប្រជាពលរដ្ឋចាត់ទុក ថាជាប្រមុខនោះម្តេចដែរ? វាគួរឲ្យសង្វេគពេកណាស់ នៅពេលដែលយើងឃើញប្រមុខបក្សប្រឆាំង ឡេឡា ឆ្វេឆ្វាដោយអត់ក្បាលដែរ ហើយបើស្ទាបទៅបេះដូងវិញ គឺគគ្រិចខ្លាំងណាស់! ម្ងៃៗមើលទៅឃើញតែគេឡើងចុះៗសហគមន៍អឺរ៉ុប ធ្វើដូចថារវល់ខ្លាំងសម្បើមណាស់ ដែលការពិតរឿងតែមួយគត់ដែលអស់លោកនោះត្រូវធ្វើ គឺរកក្បាលរបស់ខ្លួន នោះទើបដឹងថាតើចង់នាំប្រជាពលរដ្ឋទៅណា? នោះហើយគឺទស្សនវិស័យ។ រាល់ថ្ងៃនេះ មិនអត់ទេសំណួរដែលពួកគាត់ដាក់មកខ្លួនឯង តែជាប្រភេទសំណួរថា តើអញត្រូវដើរក្បាច់ណាទៀត ដើម្បីកុំឲ្យអញបាត់ប្រជាប្រិយភាពផង កុំឲ្យបាត់លាភសក្ការៈផង? គេចំណាយពេលឥតប្រយោជន៍ រត់ទៅបំពេញចិត្តប្រជាពលរដ្ឋ ណាខ្លាចថាបើឆាប់ចូលជាមួយរដ្ឋាភិបាលពេកវានឹងសម្លាប់ជីវិតនយោ-បាយរបស់ខ្លួន គឺនឹងបាត់ការគាំទ្រសម្រាប់អាណត្តិក្រោយ ណាឡេឡាបើក្រចូលពេក ក៏ត្រូវប្រឈមនឹងស្ម័គ្របក្ខពួកដែលបានសន្យាថារកតំណែងឲ្យពួកគេ ណាបើចេះតែពន្យារពេលយូរទៅៗ អត់ចេញលទ្ធផលអីសោះ ពិបាកដោះសារជាមួយប្រជាពលរដ្ឋ។

ងាកទៅអ្នកនយោបាយជើងចាស់ចាំផ្ទះវិញ ក៏មិនប្រណីដែមិនអាណិតអាសូរប្រជាពលរដ្ឋដែរ។ វាត្រូវហើយដែលអ្នកវិភាគបានវិភាគថា បើធ្វើការវះកាត់ធំ នោះអាចរកសម្លេងគាំទ្រពីប្រជាពលរដ្ឋមកវិញខ្លះ តែវាស្មើនឹងកាត់សរសៃដៃ សរសៃជើងខ្លួនឯង ដែលទីបំផុតក៏រលំគ្រេង។ ខ្ទេចហើយខ្មែរបើតែយ៉ាងៗនេះនោះ! តើជាតិយើងអាចរស់បានរហូតដល់ពេលណាលោកធំខ្មែរ និងលោកប្រជា

ពលរដ្ឋខ្មែរ?

មានតែការបែរមកពន្យល់ពង្រីកគុណភាពរបស់ប្រជាពលរដ្ឋប៉ុណ្ណោះ ទើបអាចកាត់ផ្តាច់ និងដោះស្រាយវិបត្តិខ្មែរបាន។ តើគុណភាពពលបែបណាដែលយើងត្រូវការ? ក្រៅពីចំណេះជំនាញបច្ចេកទេស យើងត្រូវបណ្តុះឲ្យប្រជាពលរដ្ឋយើងមានមូលដ្ឋានក្នុងការពិចារណាតាមបែបហេតុផលដែលឈរលើមេរៀនព្រះធម៌។ ព្រះធម៌មានតម្លៃណាស់ក្នុងការបណ្តុះការយល់ដឹង បណ្តុះនូវការពិចារណាដល់ប្រជាពលរដ្ឋ។ ការសិក្សាព្រះធម៌នឹងជួយឲ្យប្រជាពលរដ្ឋរួចផុតពីជំនឿចាក់ស្រែះតាមបែបសាសនា។ ឫសកែវចង្រៃធំមួយរបស់សាសនា នោះគឺការដឹកនាំឲ្យបរិស័ទផ្តេកផ្តួលលើគេ ពឹងលើគេដោយមិនប្រើក្បាលខ្លួនឯង។ តាំងតែពីដូនតាយើងមក តាមរយៈជំនឿស្លប់ៗ ជាហេតុមួយដែលនាំឲ្យប្រជាពលរដ្ឋពឹងតែលើកម្លាំងក្រៅខ្លួន រាប់តាំងពីរឿងផ្ទាល់ខ្លួនក្នុងផ្ទះ ដូចជាការអុចធូបសុំក្តីសុខ សុំរកស៊ីមានបាន ហើយឫសចង្រៃនេះ ធំធាត់រហូតដល់ពេលប្រជាពលរដ្ឋចង់បានប្រជាធិបតេយ្យ ក៏អុចធូបសំពះសុំពីគេដែរ។ នេះជាឥទ្ធិពលអាក្រក់នៃសាសនា។ បន្ថែមពីលើនេះ ត្រូវបណ្តុះសីលធម៌ដល់ប្រជាពលរដ្ឋ។

ក្រោយពីការបង្ក្រាបបាតុកម្មនៅផ្លូវវេងស្រេងលើកមុន វិទ្យុមួយបានធ្វើការសំភាសន៍ប្រធានគណបក្សប្រឆាំងដោយសួរថា តើលោកមានគម្រោងធ្វើបាតុកម្មទៀតទេ? គាត់ឆ្លើយថាមាន។ គេសួរបន្តថា គម្រោងនឹងធ្វើទៀតពេលណា? គាត់ឆ្លើយថា ពេលណាដែលអ្នកកាន់អំណាចគោរពច្បាប់ គោរពរដ្ឋធម្មនុញ្ញ មិនធ្វើការបង្ក្រាបឃោរឃៅទៀត គាត់នឹងដឹកនាំធ្វើបាតុកម្មបន្ត! សូមស្តាប់មើលក្បាលរបស់ប្រជាពលរដ្ឋនិយាយចុះ! នេះហើយប្រភេទមាន់ដាច់ក្បាល ហើយឆ្កេឆ្លាមិនដឹងទិសតំបន់នោះ។ បើដល់ថ្ងៃដែលគេ គោរពរដ្ឋធម្មនុញ្ញហើយ តើគាត់នៅចង់ធ្វើបាតុកម្មរកអីទៀត? ក្រែងស្រែកក្តែងៗរាល់ថ្ងៃនេះ ទាមទារឲ្យគេគោរពច្បាប់មែនទេ?

ព្រះធម៌បង្រៀនមនុស្សឲ្យមានគោលដៅជីវិតត្រឹមត្រូវ ឲ្យចេះកសាងខ្លួនទៅជាចំណែកនៃបង្គុំនៃប្រទេស ដែលសមគួរដល់ការរស់នៅ ឲ្យរស់ដោយឥស្សរៈមិនរស់បែបកញ្ជះ ឲ្យរស់ចម្រើនដល់ផែនដី និងឲ្យរស់ពេញតម្លៃដែលបានកើតជាមនុស្ស។ ប្រជាពលរដ្ឋដែលមានគុណភាព ជាមនុស្សសុចរិតស្មោះត្រង់ តែមិនស្លូតស្លាប់ ជាប្រជាពលរដ្ឋដែលមានសីលធម៌ គឺមានសីលជាប្រក្រតីនៃចិត្ត។

ដោយឈរលើគោលខាងលើនេះ យើងបាន និងកំពុងបណ្តុះបានប្រជាពលរដ្ឋដែលមានទាំងបេះដូង មានទាំងទស្សនវិស័យ ដឹងពីកាតព្វកិច្ចរបស់ខ្លួន ហើយចូលរួមបំពេញកាតព្វកិច្ចក្នុងនាមជាម្ចាស់ប្រទេស ដោយការទទួលខុសត្រូវ គឺមិនទៅធ្វើការបន់ស្រន់ បួងសួងសុំសប្បុរសពីអ្នកដឹកនាំឡើយ។ ប្រជាពលរដ្ឋប្រភេទនោះហើយដែលទៅធ្វើការជ្រើសរើសតំណាង ដែលមានទាំងបេះដូងជួយសង្គ្រោះប្រទេសជាតិប្រកបដោយទស្សនវិស័យមុតស្រួច ក្នុងការដោះស្រាយបញ្ហាប្រទេសជាតិ។

ការរួមចំណែករបស់ពួកយើងម្នាក់ៗនេះតូចខ្លាំងណាស់ ប្រៀបបានថាយើងមានតំណក់ទឹកស្អាតម្នាក់មួយតំណក់ៗ បណ្តក់ចូលទៅក្នុងសង្គម ខណៈពេលដែលមនុស្សទុច្ចរិតគេមានទុយោទឹកធំៗ បាញ់បញ្ចូលទឹកកខ្វក់មកបំពុលសង្គមខ្មែរ តែពួកយើងមានទំនុកចិត្តថា គង់មានថ្ងៃដែលទឹកស្អាតគ្រប់តំណក់របស់ពួកយើង សាយភាយកាន់តែច្រើនទៅច្រើនទៅ លប់លើតំណក់ទឹកកខ្វក់មិនខាន។ ហើយបើវាមិនអាចទេ នោះគឺប្រាកដជាវាមិនគ្រប់ហេតុឲ្យវាអាច។ បើយើងមិនដឹងថា យើងត្រូវធ្វើដំណើរសំដៅទៅទីណាទេ នោះយើងនឹងទៅដល់ទីកន្លែងមួយ ដែលមិនដឹងថាជាទីកន្លែងណានោះឯង។ បើយើងមានគោលដៅត្រឹមត្រូវច្បាស់លាស់អាចសម្រេចបានទោះ ជាយើងត្រូវចំណាយពេលយូរដើម្បីទៅដល់ ក៏វាត្រឹមតែជារឿងពេលវេលាតែប៉ុណ្ណោះ តែយ៉ាងណាក៏យើងនៅលើទីតាំងត្រឹមត្រូវ ដែលនឹងនាំទៅដល់គោលដៅរួមដែលដៅទុកមិនខាន៕

## អ្នកជានរណា?

នៅក្នុងការិយាល័យមួយ មានបុរសបួននាក់គឺ **អ្នកទាំងអស់គ្នា** **អ្នកខ្លះ** **អ្នកណាមួយ** និងគ្មាននរណាម្នាក់។ ថ្ងៃមួយមានរឿងបន្ទាន់មួយត្រូវធ្វើ។ **អ្នកទាំងអស់គ្នា** ប្រាកដណាស់ថា **អ្នកខ្លះនឹងធ្វើ**។ **អ្នកខ្លះ**ខឹងណាស់ ព្រោះវាជារឿងរបស់**អ្នកទាំងអស់គ្នា**។ **អ្នកទាំងអស់គ្នា** ក៏គិតថា **អ្នកណាមួយនឹងធ្វើ**។ រីឯ**អ្នកណាមួយ**ក៏ជឿថា **អ្នកទាំងអស់គ្នា**នឹងមិនធ្វើដែរ។

ចុងបញ្ចប់ **អ្នកទាំងអស់**គ្នាបន្ទោស **អ្នកខ្លះ** ពេលដែលគ្មាន**នរណាម្នាក់** បានធ្វើនូវអ្វីមួយ ដែល**អ្នកណាមួយ**គួរតែធ្វើ!!!

តើពួកយើងម្នាក់ៗនេះ ជានរណាមួយនៃអ្នកទាំងបួនខាងលើ។ ក្នុងប្រទេសមួយ មិនថានរណាពាក់ផ្លាកឈ្មោះអ្វី ជាអ្វី នោះទេ បើពួកយើងប្រចាំ និងមើលបំណាំគ្នាហើយ មាតុភូមិនេះច្បាស់ជារីងរៃហើយ។ ក្រៅពីបំពេញតួនាទីជាសមាជិកល្អនៃគ្រួសារមួយ ពួកយើងក៏ជាសមាជិកនៃសង្គមនេះ ជាសមាជិកនៃពិភពលោកនេះដែរ។ យើងគ្រប់ៗគ្នា "មានភារៈ" មើលថែសង្គមនេះ មិនមែនទៅតាមចង់ ឬមិនចង់ឡើយ។ **ជាតិយើងអាចរស់ ព្រោះតែយើងហ៊ានស្លាប់ដើម្បីជាតិ តែជាតិយើងនឹងស្លាប់ បើកាលណា យើងខ្លាចស្លាប់ ហើយរត់យករួចតែខ្លួនឯង**។ ត្រឹមជួយគិតជួយគួរជួយធ្វើគ្នាម្នាក់មួយដៃ ម្នាក់មួយជើង ដោយការយល់ដឹង និងការទទួលខុសត្រូវ នោះមាតុភូមិដ៏កំសត់របស់យើងប្រាកដជាអាចសង្គ្រោះបាន ដោយមិនមានការបង្ហូរឈាមមិនខាន។ ហើយសួរថា តើសង្គ្រោះទៅណា? គឺទៅរកចំណុចមួយដែល ពួកយើងទាំងអស់ អាចរស់នៅដោយស្មើភាពគ្នាក្នុងភាពជាម្ចាស់ប្រទេសបាន។ ធនធានធម្មជាតិប្រទេសយើងប៉ុណ្ណេះ វាគ្រប់គ្រាន់នឹងចិញ្ចឹមប្រជាពលរដ្ឋខ្មែរទូទាំងប្រទេសបាន តែវានឹងមិនអាចបំពេញគ្រប់តណ្ហារបស់ជនអាត្មានិយមសូម្បីត្រឹមតែម្នាក់បានឡើយ៕

## គតិផ្សេងៗ

ហេតុអ្វីបានជាអ្នកចេះតែឈូរឆរៗ ទៅតាមតែគ្នាអញ្ចឹង? ខ្ញុំមិនដឹងទេ អ្នកខាងមុខចេះតែនាំទៅ ខ្ញុំក៏ចេះតែទៅតាមគេទៅ។ អេ! អ្នកខាងមុខ! តើអ្នកកំពុងតែនាំពួកគេទៅណា? ខ្ញុំក៏មិនដឹងដែរ ពួកគេចេះតែនាំគ្នារុញគូទខ្ញុំ ហើយខ្ញុំមិនដឹងថាត្រូវធ្វើយ៉ាងមេចក៏ចេះតែដើរៗទៅ។

'Followers, why are you going with the crowd?' 'I don't know. The pioneer is leading; I just follow'. Pioneer, to where are you leading them? I don't know; the crowd push me and I just go.

សម្រាប់ខ្លួនខ្ញុំផ្ទាល់ខ្ញុំមានអារម្មណ៍ថា វាគឺជារឿងថោកទាបបំផុតដែលអ្នកនយោបាយណាមានចិត្តចង់រកផលប្រយោជន៍ផ្ទាល់ខ្លួនពីកិច្ចការនយោបាយ។

Personally, I feel that it is the most despicable thing for a politician to seek personal gains from politics.

អ្នកដឹកនាំខ្លាំងត្រូវមានទេពកោសល្យពីធម្មជាតិពីរយ៉ាងដែលមិនអាចខ្វះបាន គឺបេះដូងស្មោះត្រង់ពិតប្រាកដ និងទស្សនវិស័យភ្លឺថ្លា។

A great leader must possess two key innate qualities: an honest heart and clear-sighted vision.

បើអ្នកចូលរួមក្នុងនយោបាយដោយល្ងង់ខ្លៅ អ្នកចៀសមិនផុតពីការបោកប្រាស់ពីអ្នកនយោបាយឡើយ។

If you foolishly get involved in politics, you cannot avoid being the victim of politicians.

## ស្វែងយល់បន្ថែម

(១). វិទ្យុសំបុកឃ្មុំ FM105 MHz ភ្នំពេញ: ម៉ោង ២ ដល់ម៉ោង ៣ រសៀល

(២). គេហទំព័រ: www.camldp.org

(៣). YouTube: ខឹម វាសនា ឬ Khem Veasna

(៤). Paltalk: Room Koun Khmer និង/ឬ

(៥). សារអេឡិចត្រូនិក: camldp3@gmail.com